អកុសល នៃ អរិយធម៌

នៅចំពោះមុខ ការលូតលស់ នៃ អរិយធម៌ ជាទូទៅ និង ពុំអាចថយក្រោយបាន រ៉ាមានចោទជា ចំណោទ ជាជម្រៅ អំពី បញ្ហា នៃ ការលូតលស់ ជាវិជ្ជមាននោះ វ៉ា បំផ្លាញដោយខ្លួនឯង ហើយ បង្កើត ជារោគលក្ខណៈពិសេស សំរាប់មនុស្សលោកយើង គឺ អកុសល នៃ អរិយធម៌។

សន្ធានកម្ម[1] នៃ ភាពលូតលាស់ នៃ ទីក្រុង, បច្ចេកទេស, ការិយាល័យធិតេយ្យ, ឧស្សាហកម្ម, មូលធនិក, បុគ្គលនិយម រ៉ា ស៊ីរ្ជងបន្ទ្ចិចម្ត្ចងៗពីក្នុងអរិយធម៌ ក៏ដូចគ្នានឹង ការលូតលាស់ នៃ អរិយធម៌ដែរ។ តែ ខ្ជង អវិជ្ជមាន នៃ ហិតកម្ម (bienfaits) ដែល យើងកំពុង ក្រេបជញ្ជក់ ដោយ អស្សាទ (délices) រាល់ថ្ងៃ រ៉ា ចេះតែធំឡើងៗជានិច្ច។ អកុសល នៃ អរិយធម៌ របស់យើង គឺ កាន់តែបញ្ចេញឲយើញ ខ្ជងអវិជ្ជមាន នៃ បុគ្គលូបនីយកម្ម, បច្ចេកទេសូបនីយកម្ម, រូបិយវត្ថុបនីយកម្ម[2], ការអភិវឌ្ឍន៍ និង សុខុមាលភាព។

ដូច្ចេះ បច្ចេកទេស ដែលអាចបំរើមនុស្សគ្រប់បែបយ៉ាង បែរជា បង្ខំមនុស្សអោយរស់នៅ ក្នុង លូស៊ីក (logique) នៃ ម៉ាស៊ីន

[1] សន្ធានកម្ម; ការជួបគ្នា ; conjonction.
[2] បុគ្គលូបនីយកម្ម, បច្ចេកទេសូបនីយកម្ម, រូបិយវត្ថុបនីយកម្ម ; individualisation, technicisation, monétarisation.

សិប្បនិម្មិត ដូចជា បច្ចយនិយម, យុន្តកម្មនិយម, ឯកទេស, ផ្ទៀងពេល[3]។ លូសុិកនេះ វាបង្ខំឲមាន នៅក្នុង ការទំនាក់ទំនង បែបអនាមិក រវាង បុគ្គលនឹងបុគ្គល នៅគ្រប់ទីកន្លែង ហើយ វា កំណត់ ជា លក្ខណៈនិជ្ជយ ស្តង់ដារ និង អបុគ្គល[4] ក្នុង ភាពរាក់ទាក់ ដែល មនុស្សយើង ហាក់បីដូចជាគ្មានទំនើង ប្រឆាំង តិចជ្រើននឹងឥទ្ធិពល របស់វាសោះឡើយ។

ភាពលូតលាស់ ឧស្សាហកម្ម នាំមកនូវ ហាន:ជីវភាពខ្ពស់ ដោយ ផលិត នូវ ផលិតផល សំរាប់ប្រើប្រាស់ គ្រប់បែបយ៉ាង ជាច្រើន ហើយ មាន តម្លៃថោកល្មមនឹងអាចទិញបាន។ តែ ផលិកម្ម ច្រើនក្រៃលែងនោះ តទៅមុខ វានឹងគំរាម ពីក្រៅ ដល់ សង្គម និង មនុស្សលោក គឺ វិការភាគ (dégradation) នៃបរិស្ថាន នៅ គ្រប់មជ្ឈដ្ឋាន នៃ ជីវិតសត្វលោក ហើយ វា គំរាម ពីក្នុងផងដែរ គឺ វិការភាគ ដល់ គុណភាព នៃ ជីវិតមនុស្សលោក។ លើស ទៅទៀត ការប្រណាំង នៃ ការលូតលាស់ នៅក្នុង ក្របខណ្ឌរីកសាយ នៃ សេដ្ឋកិច្ច ពិភពលោក វាប្រល័យ នូវ អ្វី ដែលមិន គោរព លូសុិក នៃ ការប្រកួតនោះ។ ការអភិវឌ្ឍន៍ មូលធន វា ពិតជា ការបង្កើន នៃ ផលិតផល, ដំណូរ, ការទាក់ទងគ្នា; តែវា ក៏បណ្តាលឲកើត នូវ ទំនិញ្ញបនីយកម្ម ជាទូទៅ[5] រហូតមាននៅ

---

[3] លូសុិក បច្ចយនិយម, យុន្តកម្មនិយម, ឯកទេស, ផ្ទៀងពេល ; logique déterministe, mécanisme, spécialisée, chronométrée.

[4] លក្ខណៈនិជ្ជយ បមាណ និង អបុគ្គល ; critères standardisés et impersonnel.

[5] ទំនិញ្ញបនីយកម្ម ជាទូទៅ ; marchandisation généralisée.

អកុសល នៃ អរិយធម៌

ត្រង់កន្លែង អរូបិយវត្ថុ ដែលជាទឹកន្លែង គ្រប់គ្រងដោយ ជនុបត្ថម្ភ, សាមគ្គីភាព និង ទ្រព្យសាធារណ:[6]។ ទំនិញ្ចបនីយ កម្មទនោះ នាំបំផ្លាញ ជាលិកា (tissus) នៃ ភាពរាក់ទាក់ របស់ មនុស្សលោក។ ដូចយ៉ាង ទ្រព្យជាសាធារណ: ធម្មតាបំផុត ដូច យ៉ាង ទឹកសម្រាប់ពិសា, ទឹកសមុទ្រ, ខ្យល់បរិសុទ្ធ និង កំដៅព្រះ អាទិត្រ គេយកទៅធ្វើជា ទំនិញ្ច សំរាប់ ទិញ្ចលក់។ រហូត ដល់ របស់ទ្រព្យផ្ទាល់ខ្លួន ក៏អាចក្លាយជាទំនិញ្ចបានដែរ ដូចជា ទារក, កូនក្មេង, សរីរាង្គផ្សេងៗ របស់មនុស្ស ដូចជា តម្រងទឹក នោម ជាអាថ៌។

ផ្សារជំនួញ ផ្តល់ឯកសិទ្ធិ គ្រប់ឱកាស ដល់ គណនា រកចំណេញ ដែលនាំ បំបែក សាមគ្គីភាព និង មិត្តភាព ក្នុងសង្គម ដូច យ៉ាង ការលុប នៃ សេវាដោយឥតយកតំលៃ, អំណោយ ហើយ ក៏ វា បង្កើន ការរស់នៅ ត្រូវមានលុយ ជាការចាំបាច់ សំរាប់សុភម ង្គល។

ភាពលូតលាស់ នៃសេដ្ឋកិច្ច, នៃរដ្ឋ វាបំផុះ និង ជួយសម្រួល នូវ ការបង្ក នៃ ម៉ាស៊ីន បច្ចេកា-ការិយាល័យធិបតេយ្យ[7] ធំហួស ខ្នាត ក្តាប់បាន នូវអ្វី ដែលជា ឯកត្តជន, ប្លែកគេ (singulier)

---

[6] ជនុបត្ថម្ភ, សាមគ្គីភាព និង ទ្រព្យសាធារណ: ; entraides, solidarités et biens communs.

[7] Techno-bureaucratique.

និង រូបី[8] ហើយម្ខាងទៀត ផលិត នូវ ភាពមិនឲទទួលខុសត្រូវ (déresponsabilité)។

ភាពលូតលាស់ នៃ ទីក្រុង នាំមកពិត នូវ ភាពស្រស់ស្រាយ នៃ បុគ្គល, សេរីភាព និង ការកំសាន្តគ្រប់បែបយ៉ាង តែវា ក៏កំហិត នូវភាពផ្តុំគ្នា នៃប្រជាជនក្រីក្រ រស់នៅទីកន្លែងកង្វក់ដាច់ ស្រឡះពីទីកន្លែង រស់នៅ របស់អ្នកមាន។ ពិតប្រាកដណាស់ថា នៅទីក្រុងធំៗ លំអដោយ រស្មីភ្លើងណេអ៊ុង, ទូកញ្ចក់តាំងទំនិញ ប្រណិត, រោងកុនល្ហានទំនើប តែ វា ក៏ជួបប្រទះនឹង ការប ផ្លាញ្ញពី អានាមិកភាព កាន់តែខ្លាំងទៅៗ។ អាគារធំៗ សង់ផ្ទុំ គ្នាកាន់តែច្រើន ក្លាយជា ក្រុងការិយាល័យ តែ ជាយក្រុង សយនដ្ឋាន ក៏ដុះ ពាសពេញជាយក្រុង ធ្វើអោយ អត្តរស់សហ គម នៃទីក្រុង បាត់ស្ទើអស់ នូវ នរវេទយិតភាព (sensibilité humaines)។ បុគ្គលូបនីយកម្ម វាជា ហេតុទៅនិងផលព្រមគ្នា នៃ ស្វ័យភាព, សេរីភាព និង ការទទួលខុសត្រូវផ្ទាល់ខ្លួន តែវា ក៏បើកអោយឃើញខាងអាក្រក់របស់វាដែរ គឺ វិការភាគ នៃ សាមគ្គីភាពពីបុព្វេ, បរមាណូមាណូបនីយកម្មបុគ្គល[9], មជ្ឈ ត្តនិយម និង ជានិន្នាការ (tendanciellement) ទៅរក ជម្ងឺ « មហារីកអញ្ញនិយម » (métastase de l'ego) ដែលនាំ បង្កើត អោយមាន រិបត្តិ ក្នុង ការទំនាក់ទំនងគ្នាជាខ្លឹម រវាង បុគ្គល នឹងសង្គម និង បុគ្គលនឹងបុគ្គល។ ភាពមិនឲទទួលខុសត្រូវ ជា

---

[8] ឯកត្តជន (individuel), ស្លែកគេ (singulier) និង រូបី (concret).

[9] Atomisation des personnes.

ផ្តាំបំពោក នៃ មជ្ឈត្តនិយម ដែលជាមូលហេតុ នៃ វិការភាគ នៃ សីលនិជ្ជ័យ (sens moral)។ ដូច្នេះ ភាពមិនឲទទួលខុសត្រូវ និង អសីលធម៌ នោះហើយ រាបង្កើត នូវ ភាពគ្មានទទួលខុសត្រូវ និង កុទិដ្ឋិ[10]។

ការរីកចំរើនគួរកោត នៃ ចំណេះចេះដឹង តែនៅក្រោម ការគ្រោបសង្កត់ នៃ ចិត្តនាការ (pensée) នៃ ការចែកជាភាគតូចៗ និង ជាខណ្ឌ នៃចំណេះទាំងនោះ វា នាំឲខូចប្រយោជន៍ដល់ ចក្ខុវិស័យ នៃសារពើន នៃ ពុទ្ធិ របស់មនុស្សជាតិ។ ការលូតលាស់ នៃ អរិយធម៌ របស់មនុស្សយើង យ៉ាងនេះ វាអាចនាំទៅរក នូវ ឧនាភិវឌ្ឍន៍នៃបញ្ញា, ឧនាភិវឌ្ឍន៍នៃប្រមាការ[11], ឧនាភិវឌ្ឍន៍ នៃសីលធម៌ តាមចរន្ត នៃ វិការភាគ ព្រមគ្នា នៃ ភាពទទួលខុសត្រូវ និង សាមគ្គីភាព។

ភាពរីកសាយ នៃលទ្ធិប្រជាធិបតេយ្យ នៅក្នុងពិភពលោក ក្រោយពីសង្គ្រាមលោកលើកទី២ ចាប់ផ្តើម ស្រពោន អន្លោចៗ ដោយ ការដើរថយក្រោយ នៃ ការអនុវត្តន៍ ដូចយ៉ាង ការហូតអំណាច ពីពលរដ្ឋ ដោយ ពួកអ្នកជំនាញ និង ពួកអ្នកបច្ចេកទេស, វិបត្តិ នៃ ឧត្តមគតិ (គតិបណ្ឌិត និង គំរោងសង្គមនានា), វិការភាគ នៃ ទ្រព្យសាធារណ:[12] នៅក្រោម

[10] កុទិដ្ឋិ ; គំនិតផ្ទុយពីសីលធម៌។
[11] ឧនាភិវឌ្ឍន៍នៃបញ្ញា, ឧនាភិវឌ្ឍន៍នៃប្រមាការ ; sous-développement intellectuel et sous-développement affectif.
[12] Bien commun.

អកុសល នៃ អរិយធម៌

អនុភាព នៃ ដំណើរថយក្រោយ នៃ សាមគ្គីភាព និង ភាពទទួលខុសត្រូវ នៃ អធិលោក។

នៅស្រុកខ្មែរសព្វថ្ងៃ កំពុងជួបប្រទះ នូវ អកុសល នៃ អរិយធម៌ដែលបានរៀបរាប់ខាងលើនេះ។ អកុសលនេះ វា កំពុងប្ដូរ ខ្លឹមសារជាតិ និង បំផ្លាញ វប្ធម៌ខ្មែរពីបុរាណ; ការលូតលាស់ នៃសម្ភារ: ដែលខ្មែរយើង នាំគ្នាយល់ឃើញថា ជា របស់ទំនើប វាមិនបាននាំមក នូវ គំនិតសម័យនោះឡើយ ព្រោះវា ជា ការលូតលាស់ នៅក្នុង ថាមវ័ន្ត ពីក្រៅ[13] គឺថា សង្គមខ្មែរ ជាអ្នកទទួលរង ដោយគ្មាន សមត្ថភាព ដើម្បី ជ្រើសរើស អ្វី ដែលជា កុសល និង អកុសល សំរាប់ បញ្ហា របស់ខ្លួន ដូចយ៉ាងនេះ ថាមវ័ន្តពីក្រៅ វា គ្មាន អនុភាព ដើម្បី បង្កើតអោយមាន ថាមវ័ន្តពីក្នុង[14] សំរាប់ ការលូតលាស់ វប្ធម៌ទំនើប ផ្ទុយទៅវិញ វា ក្រាន់តែជា កត្តា ដើម្បី រក្សា នូវ ឧនាភិវឌ្ឍន៍នៃបញ្ហា តែប៉ុណ្ណោះ។ រស់នៅក្នុង ឧនាភិវឌ្ឍន៍នៃបញ្ហា គឺ រស់នៅក្នុង ‹វប្ធម៌ រស់រស់[15]› គឺនៅក្នុងគំនិត លួមរហូត។ អវត្តមាន នៃ ចំណង់ ‹ឧត្តមភាព› ជា ខ្សែនាយក នៃ ចិត្តនាការខ្មែរសព្វថ្ងៃ ជា ពិសេសនៅក្នុងមជ្ឈដ្ឋាន អ្នកដឹកនាំ និង អ្នកនយោបាយ។ ពួកគាត់ កំពុងនាំគ្នា បណ្ដុះ ដោយមិនដឹងខ្លួន នូវ អកុសលខ្មែរ សំរាប់បំផ្លាញ ប្រជាជាតិខ្មែរ។

---

[13] Développement dans le dynamique exogène.

[14] Le dynamique endogène.

[15] Culture de survie.